Disability Rights California

*ប្រព័ន្ធការពារ និងតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា*
*លេខទូរស័ព្ទហៅមិនអស់ប្រាក់ (800) 776-5746*

# មជ្ឈមណ្ឌលការងារអាមេរិកាំងប្រចាំរដ្ឋកាលីហ្វ័រនីញ៉ា

***ខែកុម្ភៈ ឆ្នាំ 2014 ឯកសារបោះពុម្ពផ្សាយលេខ #5521.06 - Cambodian***

## តើអ្វីជា មជ្ឈមណ្ឌលការងារអាមេរិកាំងប្រចាំរដ្ឋកាលីហ្វ័រនីញ៉ា?

មជ្ឈមណ្ឌលការងារអាមេរិកាំងប្រចាំរដ្ឋកាលីហ្វ័រនីញ៉ា (ពីមុនគេហៅថា មជ្ឈមណ្ឌលច្រកចេញចូលតែមួយដើម្បីការងារ - One-Stop Career Center) ត្រូវបានបង្កើតឡើងដោយច្បាប់វិនិយោគកម្លាំងពលកម្ម (WIA, Workforce Investment Act) ។ មជ្ឈមណ្ឌលការងារអាមេរិកាំងប្រចាំរដ្ឋកាលីហ្វ័រនីញ៉ា(AJCC, America’s Job Center of California) អនុវត្តសកម្មភាពអភិវឌ្ឍន៍កម្លាំងពលកម្មជាច្រើនផ្នែក តាមរយៈអង្គការទូទាំងរដ្ឋ និងអង្គការប្រចាំមូលដ្ឋាន ។ មជ្ឈមណ្ឌលទាំងអស់នេះ ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈវិនិយោគកម្លាំងពលកម្ម (WIB, Workforce Investment Board) ដែលក្នុងនោះមានតំណាងផ្នែកអាជីវកម្ម អង្គការពលកម្ម វិទ្យាស្ថានអប់រំ និងអង្គការសហគមន៍ ។

សមាជិក WIB ត្រូវបានតែងតាំងដោយអភិបាលរដ្ឋ ហើយមានតួនាទីជួយអភិបាលរដ្ឋក្នុងការរៀបចំផែនការទូទាំងរដ្ឋ និងរៀបចំគោលនយោបាយសមរម្យសម្រាប់ប្រតិបត្តិការរបស់មជ្ឈមណ្ឌលការងារអាមេរិកាំងប្រចាំរដ្ឋកាលីហ្វ័រនីញ៉ា AJCC ។ នាយកដ្ឋានអភិវឌ្ឍន៍ការងារ (EDD, Employment Development Department) មានការទទួលខុសត្រូវចម្បងចំពោះការងារ AJCC ប្រចាំរដ្ឋកាលីហ្វ័រនីញ៉ា ។

## តើអ្វីជាគោលបំណងរបស់ មជ្ឈមណ្ឌលការងារអាមេរិកាំងប្រចាំរដ្ឋកាលីហ្វ័រនីញ៉ា?

គោលបំណងនៃសកម្មភាព AJCC គឺដើម្បីលើកកម្ពស់លើភាពកើនឡើងចំពោះការងារ ការរក្សាទុកការងារ ការរកប្រាក់ចំណូល និងបំណិនការងាររបស់អ្នកចូលរួមក្នុងសកម្មភាពរបស់មជ្ឈមណ្ឌលនេះ ។ សកម្មភាព AJCC ត្រូវបានរៀបចំឡើង ដើម្បីលើកកម្ពស់គុណភាពកម្លាំងពលកម្ម កាត់បន្ថយការពឹងពាក់របស់ពួកគេចំពោះជំនួយសុខុមាលភាព និងជំនួយសាធារណៈផ្សេងទៀត និងបង្កើត ផលិតភាពនៃកម្លាំងពលកម្មជាតិ ។

## តើនរណាមានសិទ្ធិទទួលបានសេវាកម្មពីមជ្ឈមណ្ឌលការងារអាមេរិកាំងប្រចាំរដ្ឋកាលីហ្វ័រនីញ៉ា?

ច្បាប់ Title I នៃ WIA អនុញ្ញាតឲ្យសេវាកម្មរបស់ AJCC ផ្តល់ជូនយុវជន មនុស្សពេញវ័យ និងបុគ្គលិកដែលត្រូវនិយោជកផ្អាកការងារ ។ គឺរួមទាំងបុគ្គលដែលមានពិការភាព និងបុគ្គលដែលមិនមានពិការភាព ។

A. **យុវជន** – យុវជនដែលមានសិទ្ធិទទួលបានសេវាកម្មនេះ ត្រូវមានអាយុចាប់ពី 14 ឆ្នាំ ដល់ 21 ឆ្នាំ មានប្រាក់ចំណូលទាប ហើយយ៉ាងហោចណាស់ស្ថិតក្នុងចំណុចណាមួយ ក្នុងចំណុចទាំង 6 ដែលជាឧបសគ្គដើម្បីធ្វើការ ។

B. **មនុស្សពេញវ័យ** – មនុស្សពេញវ័យដែលមានសិទ្ធិទទួលបានសេវាកម្មនេះ ត្រូវមានអាយុចាប់ពី 18 ឆ្នាំឡើងលើ ។

C. **បុគ្គលិកដែលត្រូវបានផ្អាកពីការងារ** – បុគ្គលិកដែលត្រូវបានផ្អាកពីការងារដែលមានសិទ្ធិទទួលបានសេវាកម្មនេះ គឺជាបុគ្គលដែលត្រូវបាននិយោជកបញ្ឈប់ពីការងារ ហើយមិនទំនងជាមានឱកាសក្នុងការទទួលបានការងារចាស់របស់ខ្លួនមកវិញ ។

មេផ្ទះចំណាកស្រុក និងបុគ្គលដែលមានមុខរបរផ្ទាល់ខ្លួនក៏អាចមានសិទ្ធិទទួលបានសេវាកម្ម AJCC ដែរ ។

សេវាកម្មសម្រាប់មនុស្សពេញវ័យ និងបុគ្គលិកដែលត្រូវបានបញ្ឈប់ពីការងារ ត្រូវបានផ្តល់ជូនតាមរយៈមជ្ឈមណ្ឌលការងារអាមេរិកាំងប្រចាំមូលដ្ឋាន នៅទូទាំងរដ្ឋកាលីហ្វ័រនីញ៉ា ។ កម្មវិធីពេញមួយឆ្នាំរបស់ AJCC សម្រាប់យុវជន មានការផ្តោតលើការជួយឲ្យអ្នកទទួលផល សម្រេចបាននូវសមត្ថភាពជំនាញមូលដ្ឋាន បង្កើនចំណេះដឹងទូទៅ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបានចូលដល់ទីផ្សារពលកម្ម និងការងារ ។ កម្មវិធីនេះ មានការសង្កត់ធ្ងន់លើសេវាកម្មសម្រាប់យុវជនដែលនៅក្រៅសាលា ។

## សេវាកម្មរបស់ មជ្ឈមណ្ឌលការងារអាមេរិកាំងប្រចាំរដ្ឋកាលីហ្វ័រនីញ៉ា

AJCCs ប្រើយុទ្ធសាស្ត្រជាច្រើនខុសៗគ្នា ដើម្បីផ្តល់ជូនសេវាកម្មដែលមានភាពសមរម្យ និងប្រសិទ្ធិភាពបំផុត ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់អតិថិជននៅក្នុងសហគមន៍របស់ពួកគេ ។

- **សេវាកម្មស្នូល** ក៏មានផ្តល់ជូន ហើយអាចរួមបញ្ចូលនូវព័ត៌មានទីផ្សារពលកម្ម ការវាយតម្លៃដំបូងអំពីកម្រិតជំនាញ និងជំនួយស្វែងរកការងារ ព្រមទាំងបញ្ជូនអ្នកទទួលផលឲ្យចូលធ្វើការ ។
- **សេវាកម្មល្អិតល្អន់** គឺមានផ្តល់ជូនចំពោះអ្នកមានសិទ្ធិទទួលផលដែលគ្មានការងារធ្វើ ដែលយ៉ាងហោចណាស់បានបញ្ចប់សេវាកម្មស្នូលចំនួនមួយ តែនៅមិនទាន់អាចរកការងារបានធ្វើ ឬចំពោះបុគ្គលមានការងារធ្វើ ដែលត្រូវការសេវាកម្មបន្ថែម ដើម្បីទទួលបាន ឬរក្សាបាននូវការងារបច្ចុប្បន្ន ដែលនឹងនាំទៅរកភាពមានសមត្ថភាពផ្ទាល់ខ្លួនគ្រប់គ្រាន់ដើម្បីការងារ ។
- **សេវាកម្មបណ្តុះបណ្តាល** មានផ្តល់ជូនចំពោះអ្នកមានសិទ្ធិទទួលសេវាកម្មដែលស្ថិតក្នុងភាពតម្រូវដើម្បី អាចទទួលបានសេវាកម្មល្អិតល្អន់ តែនៅមិនទាន់អាចរកបាន ឬរក្សាបាននូវការងាររបស់ខ្លួន ។ គណនីបណ្តុះបណ្តាលបុគ្គល (ITA, Individual Training Accounts) ត្រូវបានបង្កើតឡើងដើម្បីផ្តល់ហិរញ្ញវត្ថុលើការបណ្តុះបណ្តាល ដោយផ្អែកលើជម្រើសរបស់បុគ្គល ចំពោះកម្មវិធីបណ្តុះបណ្តាលដែលបានជ្រើសរើស ។

ដើម្បីបានដឹងបន្ថែមអំពីមជ្ឈមណ្ឌលការងារអាមេរិកាំងប្រចាំរដ្ឋកាលីហ្វ័រនីញ៉ា អ្នកអាចចូលទៅក្នុងវិបសៃត៍របស់នាយកដ្ឋានអភិវឌ្ឍការងារ EDD តាមអាសយដ្ឋាន www.edd.ca.gov ។ អ្នកអាចរកមើលទីតាំង AJCC ប្រចាំមូលដ្ឋានរបស់អ្នក ដោយការបញ្ចូលហ្ស៊ិបកូដរបស់អ្នក នៅច្រកចូល “Find an America’s Job Center of California near you” ។

អ្នកក៏អាចទាក់ទងក្រុម (PABSS, Protection and Advocacy for Beneficiaries of Social Security) នៅឯអង្គការ Disability Rights California តាមទូរស័ព្ទលេខ 800-776-5746 ។

*(SSA, Social Security Administration) បានពិនិត្យឡើងវិញនូវអត្ថបទបោះពុម្ពផ្សាយខាងក្រោម ចំពោះតែភាពត្រឹមត្រូវផ្នែកបច្ចេកទេសតែប៉ុណ្ណោះ ទោះជាយ៉ាងណាក៏ដោយ ក៏ឯកសារនេះ មិនអាចចាត់ទុកថាជាឯកសារផ្លូវការរបស់ SSA ឡើយ ។*

*Disability Rights California បានទទួលថវិកាឧបត្ថម្ភពីប្រភពផ្តល់ជំនួយមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ [http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html](http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html)*